ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីថ្លែងការណ៍ព័ត៌មាន

## អ្នកនាំពាក្យក្រសួងការបរទេសថ្លែង
## «ឧក្រិដ្ឋកម្មគឺជាឧក្រិដ្ឋកម្ម ហើយវាមិនអាចទទួលបានភាពត្រឹមត្រូវសម្រាប់មូលហេតុផ្សេងនោះទេ»

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមីនាឆ្នាំ២០២៣ - អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានកត់សម្គាល់ជាមួយក្តីកង្វល់យ៉ាងខ្លាំងចំពោះអ្នកការទូតប្រទេសលោកខាងលិចមួយចំនួនដែលបានតម្លើងខ្លួនតាមទំនើងចិត្ត ពីតួនាទីការទូតធម្មតារបស់ខ្លួន ទៅធ្វើជាអនុរក្សជាក់ពិន្ទុក្រៅដែនកំណត់របស់ខ្លួន ចំពោះប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសម្ចាស់ផ្ទះ ដែលផ្ទុយទៅនឹងគោលការណ៍ទទួលស្គាល់ជាសាកល ក្នុងការគ្រប់គ្រងទំនាក់ទំនងរវាងបណ្តារដ្ឋអធិបតេយ្យ ដូចមានចែងនៅក្នុងមាត្រាទី២ (៧) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត (VCDR-1961)។

១. ការថ្លែងថា សវនាការរបស់ លោក កឹម សុខា ផ្អែកលើ «សន្ទិដ្ឋិភាពក្លែងក្លាយ» គឺជាការថ្លែងបែបរើសអើង និងមានចរិកលាក់ពុត។ ការពិត ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយសារមានការបំពានលើច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ព្រហ្មទណ្ឌតែប៉ុណ្ណោះ មិនមែនជាចេតនានយោបាយទេ។ បទសន្ទិដ្ឋិភាពជាមួយបរទេសត្រូវបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៤៣៩ និងមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ប្រទេសលោកខាងលិចក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការជ្រៀតជ្រែកពីបរទេស ដូចមានឧទាហរណ៍ជាច្រើនអំពីអ្នកនយោបាយដែលត្រូវបានកាត់ទោសចំពោះបទល្មើសដ៏អាក្រក់នេះ។ ក្នុងចំណោមនោះ គឺមានករណីរបស់ លោក Paul Manafort ។ ការវាយប្រហារពីសំណាក់រដ្ឋាភិបាលនៃប្រទេសលោកខាងលិចមួយចំនួន ទៅលើតុលាការរបស់ប្រទេសដទៃទៀត រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏មិនមែនជារឿងដែលមិនធ្លាប់កើតមានពីមុននោះទេ។

២. ការអះអាងថា ការផ្តន្ទាទោសចំពោះអ្នកនយោបាយបំពានច្បាប់ខាងលើ គឺជា «បរាជ័យនៃយុត្តិធម៌» គឺធ្វើឡើងដោយលម្អៀង និងមិនផ្អែកលើការពិត។ សវនាការចំនួន ៦៦ លើក បានប្រព្រឹត្តទៅដោយរលូន តម្លាភាព ជាសាធារណៈ និងស្របច្បាប់ ដោយមានការចូលរួមសង្កេតយ៉ាងជិតដល់ពីសំណាក់តំណាងអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល និងស្ថានទូត

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

បរទេស។ ដោយផ្អែកតាមច្បាប់ ចុងចោទទទួលបានឱកាសយ៉ាងពេញលេញសម្រាប់ការការពារតាមផ្លូវច្បាប់ ព្រមទាំងមានមេធាវីចំនួនបួនរូបផងដែរ។

៣. ភស្តុតាងទាំងអស់ត្រូវបានដាក់ជូនតុលាការ ជជែកដេញដោល និងផ្ទៀងផ្ទាត់ប្រកបដោយតម្លាភាព ល្អិតល្អន់ និងត្រឹមត្រូវ ដើម្បីស្វែងរកការពិត។ ក្នុងចំណោមភស្តុតាងទាំងនោះ ភស្តុតាងមួយដែលត្រូវបានផ្សព្វផ្សាយតាម "បណ្តាញផ្សព្វផ្សាយCBN" នៅឆ្នាំ២០១៣ ហើយដែលត្រូវបានពិរុទ្ធជនទទួលស្គាល់ថាត្រឹមត្រូវពិតប្រាកដ បង្ហាញថា ខ្លួនពិតជាបានទទួលការណែនាំ និងការគាំទ្រពីបរទេស ដើម្បីអនុវត្តគម្រោងការជាជំហានៗ ក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់។ ឧក្រិដ្ឋកម្មគឺជាឧក្រិដ្ឋកម្ម ហើយវាមិនអាចទទួលបានភាពត្រឹមត្រូវសម្រាប់បុព្វហេតុផ្សេងនោះទេ។

៤. បើនិយាយអំពីវិធានក្នុងទំនាក់ទំនងអន្តរជាតិវិញ ការអត្ថាធិប្បាយបែបនយោបាយរបស់បេសកជនបរទេសខាងលើ មិនថាកើតចេញពីការភាន់ច្រលំ ឬភាពអំណួត គឺជាការរំលោភលើមាត្រា ៤១(១) នៃ " អនុសញ្ញាទីក្រុងវីយ៉ែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត" ដែលបានចែងថា អ្នកការទូត «មានកាតព្វកិច្ចមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ» ហើយដែលតំណាងមកពីប្រទេសមានអារ្យធម៌មួយ មិនថាតូចឬធំ ត្រូវតែប្រកាន់ខ្ជាប់ឱ្យបានពេញលេញ។

៥. ទោះបីជាអវត្តមានអ្នកនយោបាយពីរឬបីរូបដែលល្មើសនៅក្រោមក្រមព្រហ្មទណ្ឌ ឬត្រូវបានហាមឃាត់មិនឱ្យធ្វើនយោបាយ ដោយសារការបំពានច្បាប់ កម្ពុជានៅតែប្តេជ្ញាចិត្តឥតងាករេក្នុងការរៀបចំការបោះឆ្នោតជាតិនៅក្នុងខែកក្កដាខាងមុខនេះ ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព និងឆ្លុះបញ្ចាំងយ៉ាងពេញលេញពីឆន្ទៈរបស់ប្រជាពលរដ្ឋ៕